# នាទីរក្សាវប្បធម៌ខ្មែរ

រំលឹកកូនចៅ កស្តាងក្រឡៅ គឺជាតិខេមរា
CCD ខ្ញុំ សូមចិត្តរក្សា វប្បធម៌ដូនតា ទុកតប្រាកដ។

របាំអប្សារា ក្ងោករបាំស្វា ត្រុតគោះមិនហត់

ភ្លេងប្រពៃណីយ តាក់តែងហ្មត់ចត់ យើងរួមកំណត់ រក្សាបន្ត។

ឯក្បាច់រចនា រំលេចលើក្ដា ក្រណាត់និងថ្ម

ផុសល្អត្រដែត អមដោយអក្សរ ទោះរូបកិន្នរ ស្តែងស្រីខ្មែរពិត។

រីហូលផាមួង ពាស្ត្រនិងក្រុមហ្លួង ប្រើដោយពេញចិត្ត

ខ្វះស្លៀកចង់ក្បិន សំពត់ប្រណិត អាវខ្លីវែងជិត ត្បិតពិតជាខ្មែរ។

ជាតិយើងខេមរា មានដែនរដ្ឋា នៅអាស៊ី តែ

ស្ថិតទិសអគ្នេយ៍ ប្រាង្គប្រាសាទខ្មែរ ល្បីល្បាញឥតល្ហែ តាំងពីបូរាណ។

កូនចៅជាន់ក្រោយ សូមកុំបណ្តោយ រក្សាអោយបាន

សិល្បៈវប្បធម៌ ខ្មែរយើងគ្រប់ប្រាណ ជ្រោងខ្ពស់ថ្កើងថ្កាន ខ្មែរបានគង់វង្ស។

បុព្វបុរស ទុកកេរ្តិ៍ទាំងអស់ អោយកូនទ្រទ្រង់

កេរ្តិ៍មានតម្លៃ ពឹងលើឆោមយង់ រក្សាអោយគង់ វប្បធម៌ខេមរា៕

---

*និពន្ធដោយសមាជិក CCD Saturday 14th, 2007.*